**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៧៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលមាត្រា ២ថ្មី នៃអនុក្រឹត្យលេខ ៤៨ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០០៨ ស្តីពីការកែសម្រួលមាត្រា ២ នៃអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការបង្កើតគណៈកម្មាធិការជាតិបណ្តុះបណ្តាល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការបង្កើតគណៈកម្មាធិការជាតិបណ្តុះបណ្តាល
- បានឃើញអនុក្រឹត្យលេខ ៤៨ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០០៨ ស្តីពីការសម្រួលមាត្រា ២ នៃអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការបង្កើតគណៈកម្មាធិការជាតិបណ្តុះបណ្តាល
- តាមសំណើរបស់ប្រធានគណៈកម្មាធិការជាតិបណ្តុះបណ្តាល

## សម្រេច

**មាត្រា មួយ.-**

ត្រូវបានកែសម្រួលមាត្រា ២ថ្មី នៃអនុក្រឹត្យលេខ ៤៨ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០០៨ ស្តីពីការសម្រួលមាត្រា ២ នៃអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការបង្កើតគណៈកម្មាធិការជាតិបណ្តុះបណ្តាល ដូចតទៅ ÷

**មាត្រា ២ថ្មី(ពីរ)..**

សមាសភាពនៃគណៈកម្មាធិការជាតិបណ្តុះបណ្តាល មានដូចខាងក្រោម ÷

| | |
|---|---|
| ១- ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| ២- តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | អនុប្រធាន |
| ៣- តំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | អនុប្រធាន |
| ៤- តំណាងក្រសួងអប់រំ យុវជន និងកីឡា | អនុប្រធាន |
| ៥- ប្រធានសភាមុខរបរ និងមីក្រូសហគ្រាស | អនុប្រធាន |
| ៦- តំណាងនិយោជក | អនុប្រធាន |
| ៧- តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៨- តំណាងក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៩- តំណាងក្រសួងសុខាភិបាល | សមាជិក |
| ១០- តំណាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ១១- តំណាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ១២- តំណាងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ១៣- តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១៤- តំណាងក្រសួងទេសចរណ៍ | សមាជិក |
| ១៥- តំណាងក្រសួងកិច្ចការនារី | សមាជិក |
| ១៦- តំណាងក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១៧- តំណាងក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ១៨- តំណាងក្រសួងផែនការ | សមាជិក |
| ១៩- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ២០- តំណាងក្រសួងបរិស្ថាន | សមាជិក |
| ២១- តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ២២- ប្រធានទីភ្នាក់ងារជាតិមុខរបរ និងការងារ | សមាជិក |
| ២៣- តំណាង ៤រូប របស់និយោជក | សមាជិក |
| ២៤- តំណាង ១រូប របស់សភាពាណិជ្ជកម្ម | សមាជិក |
| ២៥- តំណាង ២រូប របស់នាយោជិត | សមាជិក |
| ២៦- តំណាង ៣រូប ជាអ្នកផ្តល់ការបណ្តុះបណ្តាល | សមាជិក |
| ២៧- តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | នាយកប្រតិបត្តិ។ |

គណៈកម្មាធិការជាតិអាចអញ្ជើញតំណាង ៣រូប របស់អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល ចូលរួមបាន។

គណៈកម្មាធិការជាតិនេះ មានអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាលេខាធិការដ្ឋានអចិន្ត្រៃយ៍។

**មាត្រា ពីរ..**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា បី..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ គណៈកម្មាធិការជាតិបណ្ដុះបណ្ដាល អភិបាលរាជធានី-ខេត្ត ត្រូវទទួលបន្ទុក អនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ៨ ឆ្នាំ២០១០

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល :***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា បី*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ* ✓